

# ការវាយតម្លៃផែនការសកម្មភាពជាតិស្តីពី ការអប់រំពហុភាសានៅកម្ពុជា

## ខែ ឧសភា ឆ្នាំ ២០១៩

*ថតដោយ © UNICEF Cambodia/2018/Jessica Ball*

## សេចក្តីសង្ខេបការវាយតម្លៃ

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា (ហៅកាត់ថា MENAP) ឆ្នាំ ២០១៤-២០១៨ ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដោយរាជរដ្ឋាភិបាលកម្ពុជា កាលពីឆ្នាំ ២០១៥។ ផែនការនេះ ត្រូវបាន អនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយនឹងអង្គការយូនីសេហ្វកម្ពុជា និងអង្គការ CARE ដោយមានការពិគ្រោះយោបល់ជាមួយនឹងតួអង្គពាក់ព័ន្ធដទៃទៀត ក្នុងប្រទេសកម្ពុជា។ គោលដៅចម្បង គឺដើម្បីឱ្យកុមារី និងកុមារជនជាតិដើមភាគតិច អាចទទួលបានការអប់រំប្រកបដោយអត្ថន័យ តាមរយៈការផ្តល់ឱ្យពួកគេនូវការអប់រំពហុភាសា នៅមត្តេយ្យសិក្សា និងបីឆ្នាំដំបូងនៃបឋមសិក្សា។ កម្មវិធីសិក្សាសម្រាប់ការអប់រំពហុភាសា ត្រូវបានអនុវត្ត ដោយប្រើប្រាស់ភាសាខ្មែរ និងភាសាជនជាតិដើមភាគតិចចំនួនប្រាំ (ព្នង កាវ៉ែត គ្រឹង ទំពួន និងព្រៅ)។ កម្មវិធីសិក្សា

*រូបភាពទី ១៖ ស្ថានចម្លងដែលផ្តល់ដោយផែនការយុទ្ធសាស្ត្រជាតិស្តីពីការអប់រំពហុភាសា៖ ប្រេកខ្លី ដើម្បីទទួលបានការអប់រំ*




ដែលប្រើប្រាស់ ក្នុងការអប់រំពហុភាសា ត្រូវបានអនុវត្ត នៅ

តាមសាលាមត្តេយ្យ និងបឋមសិក្សា ដែលមានកុមារជនជាតិដើមភាគតិចរស់នៅ ច្រើន ក្នុងខេត្ត មណ្ឌលគិរី រតនគិរី ក្រចេះ និងស្ទឹងត្រែង ហើយក៏បានអនុវត្តផងដែរនៅតាមសាលា មត្តេយ្យ ចំនួន ៦ ក្នុងស្រុកមួយ ក្នុងខេត្តព្រះវិហារ។ គំនិតផ្តួចផ្តើមនេះ ប្រើប្រាស់គំរូស្ពានចម្លង (bridging model)ដែល កុមារចាប់ផ្តើមរៀនដោយប្រើប្រាស់ភាសាជនជាតិដើមរបស់ពួកគេ ហើយរៀនជាភាសាជាតិ (ភាសាខ្មែរ) បន្តិចម្តង និងរៀនតាមកម្មវិធីសិក្សាជាតិទាំងស្រុង នៅថ្នាក់ទី ៤។

ផែនការនេះគឺ ពុំដែលធ្លាប់មាន នៅអាស៊ីអាគ្នេយ៍ឡើយ ព្រោះថារដ្ឋាភិបាលប្តេជ្ញាយកភាសាជនជាតិដើមភាគតិច មកប្រើប្រាស់ ដើម្បីជំរុញលើកកម្ពស់សមធម៌។ វាមានសង្គតិភាពជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការនេះ ក៏មានសង្គតិភាព ជាមួយនឹងក្របខ័ណ្ឌសិទ្ធិអន្តរជាតិជាច្រើន និងមានការគាំទ្រពីភស្តុតាង បានពីការស្រាវជ្រាវអន្តរជាតិ ដែលបង្ហាញថាការអប់រំពហុភាសា ចូលរួមចំណែកជារដ្ឋមាន ចំពោះការ ការចូលរួមរបស់កុមារដែលនិយាយភាសាភាគជនជាតិដើមភាគតិចក្នុងការអប់រំ និងការរួមក្នុងសង្គម ។ ផែនការនេះ គឺជាជំហានដ៏មុតមាំមួយ ដែលរៀបចំឡើងផ្អែកតាមព័ត៌មានត្រឹមត្រូវ ហើយក៏ជាផែនការដំបូងបំផុត ក្នុងតំបន់អាស៊ីអាគ្នេយ៍ផងដែរ។

*រូបភាពទី ២៖ ផែនទីបង្ហាញពីទីតាំងសម្រាប់វាយតម្លៃ*




ក្នុងរយៈពេលបួនឆ្នាំកន្លងមក ផែនការនេះមានគោលបំណង ឱ្យកុមារកាន់តែមានឱកាសទទួលបានការអប់រំ ដោយប្រើភាសាកំណើតរបស់ពួកគេ រួមនឹងភាសាខ្មែរផង តាមរយៈការបង្កើនតម្រូវការសេវាអប់រំពហុភាសា ក្នុងចំណោមកុមារ មាតាបិតា សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន និងអាជ្ញាធរមូលដ្ឋាន (ដែលជាអ្នកមានសិទ្ធិចម្បង) និងតាមរយៈការកសាងសមត្ថភាពមន្ត្រីអប់រំនៅថ្នាក់ជាតិ ខេត្ត និងស្រុក និងគ្រូបង្រៀន (អ្នកកាន់ភារកិច្ចចម្បង) ក្នុងការគ្រប់គ្រង ផ្តល់ និងពិនិត្យតាមដានសេវាអប់រំពហុភាសា។ នៅពេលដែលផែនការនេះបញ្ចប់អាណត្តិរបស់ខ្លួន ក្នុងខែ កក្កដា ឆ្នាំ ២០១៨ អង្គការយូនីសេហ្វកម្ពុជា ក្នុងនាមតំណាងឱ្យក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឱ្យមានការវាយតម្លៃដោយឯករាជ្យ ដើម្បីកំណត់ថា តើការអនុវត្តផែនការនេះ ធ្វើទៅបានល្អកម្រិតណា។ ការវាយតម្លៃនេះ ផ្តោតលើខេត្តចំនួនបួន ដែលបានអនុវត្តផែនការនេះ នៅតាមសាលាមត្តេយ្យ និងសាលាបឋមសិក្សា។

## វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់ធ្វើការវាយតម្លៃ

ការវាយតម្លៃនេះ យកសិទ្ធិ និងទ្រឹស្តីធ្វើជាមូលដ្ឋាន និងប្រើប្រាស់វិធីសាស្ត្រ មិនមែនពិសោធបែប

ចម្រុះ និងគោលវិធី iterative-inductive ដែលផ្តល់

*រូបភាពទី ៣៖ ទំហំសំណាកគំរូ*

**ការកំណត់សំណាកគំរូសាលា**

- ២៤ សាលាបឋមសិក្សាបង្រៀនពហុភាសានៅក្នុងស្រុកចំនួន១៤
- ១១ សាលាមត្តេយសិក្សាបង្រៀនពហុភាសានៅក្នុងស្រុកចំនួន៨
- ៤សាលាបឋមសិក្សាមិនមានបង្រៀនពហុភាសានៅដើម្បីប្រៀបធៀប

**ការធ្វើការស្រាវជ្រាវ**

- សរុប៖ អ្នកចូលរួម ១២២ នាក់ (ស្រី ៥៧ នាក់ ស្មើនឹង ៤៧%)
- អ្នកកាន់កាតព្វកិច្ច និងអ្នកកាន់សិទ្ធិចម្រុះលាយគ្នា

**ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ**

- សរុប៖ អ្នកចូលលរួម ៤១ នាក់ (ស្រី ១៤ នាក់ ស្មើនឹង ៣៤%)
- ភាគច្រើន ជាអ្នកកាន់កាតព្វកិច្ច និងដៃគូអភិវឌ្ឍន៍។

**ការអង្កេតមើលដោយផ្ទាល់**

- អង្កេតមើលតាមសាលាបឋមសិក្សាចំនួន២៨ និងមត្តេយ្យសាលាចំនួន ១១

លទ្ធភាពឱ្យគេអាចធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ទិន្នន័យដែលបានពីប្រភពផ្សេងៗគ្នា។ វិធីសាស្ត្រដែលប្រើប្រាស់ មានដូចជា ការពិនិត្យលើឯកសារពាក់ព័ន្ធ ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ការពិភាក្សាក្រុមគោលដៅ ការប្រើប្រាស់សំណួរអង្កេត និងសិក្ខាសាលាប្រមូលលទ្ធផល។ ការអនុវត្តវិធីសាស្ត្រនេះ មានការចូលរួមពីអ្នកចូលរួមសរុប ៦៩៦ នាក់ ក្នុងនោះមានកុមារី និងស្ត្រី ៣១៧ នាក់ (ស្មើនឹង ៤៥%)។ មានការប្រមូលទិន្នន័យ ពីសាលាអប់រំពហុភាសា និងសាលាមត្តេយ្យ ដោយប្រើប្រាស់ យុទ្ធសាស្ត្ររៀបចំសំណាកគំរូ ដែលធានាបាននូវភាពចម្រុះក្នុងកម្រិតអតិបរមា។

ការប្រមូលទិន្នន័យពីទីវាល ចាប់ផ្តើមធ្វើឡើង ពីខែ សីហា រហូតដល់ខែ តុលា ឆ្នាំ ២០១៨។ ការវាយតម្លៃនេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ ដែលមានការចូលរួមពីជនជាតិដើមភាគតិច ដូចជា ការបង្កើតក្រុមការងារក្នុងស្រុក ដែលមានស្ត្រីជនជាតិដើមភាគតិចចំនួនប្រាំនាក់ និងបុរសជនជាតិដើមភាគតិចចំនួនប្រាំនាក់ ជាសមាជិក និងមានការប្រើប្រាស់ការនិទានរឿង ជាលក្ខណៈបុគ្គល និងជាក្រុម សម្រាប់ប្រមូលព័ត៌មានពីកុមារ និងមនុស្សពេញវ័យជនជាតិដើមភាគតិច អំពីបទពិសោធន៍របស់ពួកគេពាក់ព័ន្ធនឹងការអប់រំពហុភាសា។ ក្នុងរយៈពេលនៃការវាយតម្លៃទាំងមូល មានការអនុវត្តតាមស្តង់ដាររបស់ក្រុមវាយតម្លៃនៃអង្គការសហប្រជាជាតិ និងនីតិវិធីសម្រាប់ស្តង់ដារក្រមសីលធម៌របស់អង្គការយូនីសេហ្វ។

## គោលបំណងនៃការវាយតម្លៃ

ការវាយតម្លៃនេះ ផ្តោតលើដំណាក់កាលផង និងលទ្ធផលចុងក្រោយផង។ គោលបំណងចម្បងនៃការវាយតម្លៃនេះ គឺដើម្បីស្វែងយល់ថា តើមានការអនុវត្តផែនការនេះបានល្អកម្រិតណា ដើម្បីប្រមូលព័ត៌មាន សម្រាប់កំណត់ទិសដៅយុទ្ធសាស្ត្រនាពេលអនាគត។

- វាយតម្លៃថាតើផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា បានសម្រេចគោលបំណងរបស់ខ្លួនក្នុងកម្រិតណា និងកំណត់ពីកត្តាអំណោយផល ឧបសគ្គ និងចំណុចរាំងស្ទះនានា
- ពិនិត្យឡើងវិញ និង បញ្ជាក់ពីយុទ្ធសាស្ត្រ និងសកម្មភាពដែលបានអនុវត្ត ដើម្បីពង្រឹងការអប់រំពហុភាសា និងគិតបកក្រោយ ដើម្បីរៀបចំទ្រឹស្តីនៃការផ្លាស់ប្តូរ សម្រាប់ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសានេះ។

- វាយតម្លៃលើការគាំទ្រពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដល់ការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា រួមទាំងការគាំទ្រ ដែលផ្តល់ដោយអង្គការយូនីសេហ្វ និងតួអង្គពាក់ព័ន្ធដទៃទៀត។
- ចងក្រងមេរៀនដែលទទួលបាន សម្រាប់ប្រើប្រាស់ក្នុងការរៀបចំផែនការថ្មីដែលមានរយៈពេលប្រាំឆ្នាំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងលើកកម្ពស់ការសិក្សារៀនសូត្រ ក្នុងតំបន់ទាំងមូល។

អ្នកប្រើប្រាស់លទ្ធផល ដែលបានពីការវាយតម្លៃនេះ រួមមានក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ ដែលមានបំណងចង់ស្វែងយល់ពីជំហានដែលបានត្រួសត្រាយរួចសំខាន់ៗ ដែលត្រូវបានធ្វើឡើងក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ការទទួលបានការអប់រំប្រកបដោយគុណភាព និងសមធម៌ សម្រាប់កុមារជនជាតិដើមភាគតិច។

លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនេះ រួមមានភាពពាក់ព័ន្ធ ភាពស័ក្តិសិទ្ធ ប្រសិទ្ធភាព ផលជះរយៈពេលវែង និរន្តរភាព សមភាពយេនឌ័រ និងសមធម៌។

## លទ្ធផលរកឃើញនៃការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន

### ភាពពាក់ព័ន្ធ៖

កុមារ សមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន យល់ស្របក្នុងកម្រិតខ្ពស់ថា ការអប់រំពហុភាសានាំឱ្យមានការចូលរួមកាន់តែសកម្ម ក្នុងសកម្មភាពនានា ក្នុងសាលារៀន និងនាំឱ្យមានការទទួលបានការរៀនសូត្រ ប្រកបដោយអត្ថន័យ។

កម្មវិធីសិក្សាដែលប្រើប្រាស់ ក្នុងការអប់រំពហុភាសា បានទទួលការសាទរជាខ្លាំង ព្រោះតែខ្លឹមសាររបស់វាមានទំនាក់ទំនងជាមួយនឹងវប្បធម៌។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីសិក្សានេះ អាចមានភាពងាយស្រួលពេក និងត្រូវការបន្ថែមខ្លឹមសារវប្បធម៌ថ្មីៗ ដែលមានលក្ខណៈសម្បូរបែប ដែលកុមារជនជាតិដើម ឪពុកម្តាយ និងក្រុមជនជាតិដើមភាគតិច មានឆន្ទៈផ្តល់ជូន។

អ្នកកាន់សិទ្ធិចម្បង និងអ្នកកាន់ភារកិច្ចនៅថ្នាក់ក្រោមជាតិមួយចំនួន មើលឃើញពីហេតុផល សម្រាប់ពង្រីកការអប់រំពហុភាសាដល់ថ្នាក់ទី ៦ ក្នុងទ្រង់ទ្រាយតូចសាកល្បងសិន។

### ភាពស័ក្តិសិទ្ធិ៖

មានការសម្រេច ទៅតាមចំណុចដៅនានា ដូចជាការពង្រីកបរិមាណនៃការផ្តល់សេវាអប់រំពហុភាសាជាដើម។

សាលាមត្តេយ្យដែលផ្តល់ការអប់រំពហុភាសា ពុំទាន់បានបង្ហាញពីសក្តានុពលរបស់ខ្លួននៅឡើយ។ ការពឹងអាស្រ័យលើមូលនិធិឃុំ និងការខ្វះការផ្សារភ្ជាប់ទំនាក់ទំនងក្នុងលក្ខណៈជាប្រព័ន្ធ ជាមួយនឹងសាលាបឋមសិក្សា គឺជាឧបសគ្គរាំង ដល់ការបង្កើនភាពស័ក្តិសិទ្ធក្នុងខេត្តបី ក្នុងចំណោមខេត្តទាំងបួន។ ប្រកាស (លេខ ២៤៥) ដែលជាប្រកាសថ្មី ដាក់ចេញនូវក្របខ័ណ្ឌសម្រាប់

បង្កើនគុណភាព និងបំលែងមត្តេយ្យសិក្សាជាសាលារដ្ឋ ដែលមានទីតាំងរួមគ្នាជាមួយនឹងសាលាបឋមសិក្សា។

**ប្រសិទ្ធភាព៖**

មានការប្រមូលកៀរគរអ្នកកាន់ភារកិច្ច នៅថ្នាក់ក្រោមជាតិទាំងអស់ ក្នុងការផ្តល់ការអប់រំពហុភាសានៅតាមសាលាបឋមសិក្សា ដែលផ្តល់សេវាដល់កុមារជនជាតិដើមភាគតិចយ៉ាងហោចណាស់ ៦០ ភាគរយ។

ចំណាយប្រតិបត្តិការ មិនជាច្រើនជាងសាលាដែលពុំបានផ្តល់ការអប់រំពហុភាសាឡើយ ប៉ុន្តែមានការលើកឡើងថា មានការខ្វះខាតថវិកា សម្រាប់ផ្តល់ការបណ្តុះបណ្តាលគ្រូ ផ្តោតលើភាសាមួយចំនួន ការពិនិត្យតាមដាន និងធនធានសម្រាប់បង្កើនអក្ខរកម្មភាសាជនជាតិដើមភាគតិច។

សាលាគរុកោសល្យខេត្ត មានសក្តានុពលដែលពុំទាន់បានប្រើប្រាស់នៅឡើយ សម្រាប់សម្រេចគោលដៅពង្រីកការទទួលបានការអប់រំ ប្រកបដោយគុណភាព ដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច និងភាសាខ្មែរ។

អង្គភាពអប់រំនៅថ្នាក់ក្រោមជាតិ មានទឹកចិត្ត និងសមត្ថភាពក្នុងការផ្តល់ការបណ្តុះបណ្តាល ពិនិត្យតាមដាន និងផ្តល់ការគាំទ្រដល់ការអប់រំពហុភាសា ប្រសិនបើអង្គភាពទាំងនេះទទួលបានការគាំទ្រហិរញ្ញវត្ថុ និងការគាំទ្របច្ចេកទេសគ្រប់គ្រាន់ពីថ្នាក់ជាតិ។

អ្នកកាន់ភារកិច្ច ហាក់បីដូចជាពុំបានអនុវត្តការងារដោយប្រើប្រាស់ផែនការអនុវត្ត ដែលមានការប៉ាន់ប្រមាណចំណាយលម្អិតនោះឡើយ។

**និរន្តរភាព៖**

តម្រូវការអប់រំពហុភាសា នៅកម្រិតបឋមសិក្សា ហាក់បីដូចជាមានលើសពីចំនួនគ្រូបង្រៀន និងគ្រូឧទ្ទេសជនជាតិដើមភាគតិចដែលមានសមត្ថភាព ដែលអាចផ្គត់ផ្គង់ឱ្យបាន ស្របពេលដែលសាលាគរុកោសល្យខេត្តមិនទាន់បានចូលរួមក្នុងការងារនេះនៅឡើយ។

នាយកដ្ឋានអប់រំពិសេស កំពុងស្ថិតនៅដំណាក់កាលដំបូងៗនៅឡើយ ក្នុងការអភិវឌ្ឍសមត្ថភាពបច្ចេកទេស សមត្ថភាពដឹកនាំ និងសមត្ថភាពស្វែងរកការគាំទ្រ។ នាយកដ្ឋាននេះក៏នៅខ្វះសមត្ថភាពភាសាជនជាតិដើមភាគតិច ដែលត្រូវការជាចាំបាច់សម្រាប់លើកទឹកចិត្តពិនិត្យតាមដាន ផ្តល់ការណែនាំ និងពង្រីកក្រុមគ្រូបង្រៀនផងដែរ។

**ផលជះរយៈពេលវែង៖**

ការអប់រំពហុភាសា បានផ្តល់នូវការអប់រំប្រកបដោយអត្ថន័យដល់កុមារជនជាតិដើមភាគតិច ព្រោះលទ្ធផលបានបង្ហាញថា អ្នកកាន់សិទ្ធិចម្បងមានការចូលរួមច្រើនជាងមុន។

បច្ចុប្បន្ននេះ មនុស្សពេញវ័យជនជាតិដើមភាគតិច កំពុងស្វែងរកការគាំទ្រ ដើម្បីចេះភាសារបស់ខ្លួន។

អត្រាវត្តមានទាបក្នុងរដូវដាំដុះ និងប្រមូលផលអំពាវនាវឱ្យមានការឆ្លើយតប ដែលមានលក្ខណៈច្នៃប្រឌិត

ថ្មី ដូចជា ការផ្តល់ភាពបត់បែនពីអាជ្ញាធរអប់រំ ដើម្បីផ្តល់លទ្ធភាពឱ្យមានការសាកល្បងប្រើប្រាស់ប្រតិទិនសិក្សា

*រូបភាពទី ៤៖ ការចុះឈ្មោះចូលរៀនក្នុងការអប់រំពហុភាសាមានការកើនឡើងពីឆ្នាំ ២០១៥ - ២០១៨ ក្នុងខេត្តភាគឦសានទាំងបួន បើធៀបនឹងសាលារៀនដែលពុំផ្តល់ការអប់រំពហុភាសា*




សមស្របតាមស្ថានភាពនៅមូលដ្ឋាន (បែបវិមជ្ឈការ)។

អ្នកកាន់ភារកិច្ចមួយចំនួន យល់ថា ការអប់រំពហុភាសា គឺជាយុទ្ធសាស្ត្ររយៈពេលខ្លី ដែលមានគោលបំណងត្រឹមតែផ្តល់ជា "ស្ពានចម្លង" ឱ្យកុមារជនជាតិដើមភាគតិច អាចទៅចូលរួមរៀនជាមួយនឹងកុមារជនជាតិខ្មែរប៉ុណ្ណោះ។ គំរូបែបនេះអាចបង្កហានិភ័យ ដល់ការធានានិរន្តរភាពការអប់រំពហុភាសា។

## សិទ្ធិមនុស្ស និងសមធម៌យេនឌ័រ៖

ការអប់រំពហុភាសាជួយឱ្យសម្រេចសិទ្ធិរបស់កុមារជនជាតិដើមភាគតិច ក្នុងការទទួលបានការអប់រំប្រកប ដោយអត្តន័យ ព្រមទាំងផ្តល់ការងារ និងតួនាទីដល់ស្ត្រីជនជាតិដើមភាគតិចក្នុងសហគមន៍។

កុមារីមានការចូលរួមក្នុងការអប់រំពហុភាសាច្រើនជាងកុមារាបន្តិច ហើយវាដូចគ្នានឹងនិន្នាការនៅថ្នាក់ជាតិដែរ។

បើតាមរបាយការណ៍នានា កុមារីគឺជាអ្នកចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពនានាក្នុងថ្នាក់រៀន នៅពេលដែលពួកគេយល់ និងអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគ្រូ។

ក្នុងការអប់រំពហុភាសា ស្ត្រីជនជាតិដើមភាគតិចបំពេញតួនាទីជាគ្រូបង្រៀន និងជាសមាជិកគណៈកម្មាធិការទ្រទ្រង់សាលារៀន។

## សេចក្ដីសន្និដ្ឋានសំខាន់ៗ



**ភាពពាក់ព័ន្ធ៖** កុមារី និងកុមារជនជាតិដើមភាគតិច កាន់តែអាចទទួលបានការអប់រំ ជាភាសា ដែលពួកគេអាចយល់បាន ជាមួយគ្រូដែលពួកគេអាចកសាងទំនាក់ទំនងជាមួយ និងប្រើប្រាស់កម្មវិធីសិក្សាដែលផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងវប្បធម៌របស់ពួកគេ។



**ភាពស័ក្តិសិទ្ធិ៖** ប្រព័ន្ធអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចពង្រីកការផ្ដល់សេវាអប់រំពហុភាសា បើទោះជាការធានាគុណភាពតម្រូវឱ្យមានការអនុវត្តយុទ្ធសាស្ត្រដែលមិនសមស្របទាំងស្រុង ជាមួយនឹងផែនការសកម្មភាពជាតិស្ដីពីការអប់រំពហុភាសាបច្ចុប្បន្ននេះក៏ដោយ។ អង្គភាពដែលទទួលខុសត្រូវលើការអនុវត្តចាំបាច់ត្រូវបង្កើតនូវប្រព័ន្ធសម្រាប់ធ្វើការប៉ាន់ប្រមាណពីចំណាយក្នុងការប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍ស្តង់ដារ។



**ប្រសិទ្ធភាព៖** អង្គភាពអប់រំនៅថ្នាក់ក្រោមជាតិ មានទឹកចិត្តបំពេញការងារ ហើយស្ថាប័នមានសមត្ថភាព ក្នុងការផ្ដល់ការបណ្ដុះបណ្ដាល ការពិនិត្យតាមដាន និងការគាំទ្រដល់ការអប់រំពហុភាសា ប្រសិនបើអង្គភាពទាំងនេះ ទទួលបានការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសគ្រប់គ្រាន់។



**លទ្ធផលរយៈពេលវែង៖** សារដែលមានភាពច្បាស់លាស់របស់រដ្ឋាភិបាលដែលបង្ហាញពីការគាំទ្រដល់ការផ្ដល់ការអប់រំ ដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច តាមរយៈការរៀបចំនូវផែនការដែលត្រូវផ្សព្វផ្សាយឱ្យបានច្បាស់លាស់ ការជំរុញឱ្យមានការចូលរួមពីអង្គការជនជាតិដើមភាគតិច និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយ អាចផ្ដល់ការលើកទឹកចិត្តយ៉ាងច្រើនដល់មាតាបិតា និងកុមារជនជាតិដើមភាគតិច ដើម្បីឱ្យពួកគេផ្ដល់តម្លៃដល់ការរៀនសូត្រ។



**និរន្តរភាព** ភាពដឹកនាំដែលមានទស្សន និងការគ្រប់គ្រងប្រកបដោយសមត្ថភាព នៅថ្នាក់ជាតិ និងការបង្កើនការគាំទ្រដល់អង្គភាពនៅថ្នាក់ក្រោមជាតិ ដើម្បីធានាថាការកើនឡើងនូវបរិមាណនៃការផ្ដល់សេវា នឹងមិនដើរលឿនជាងកែលម្អគុណភាពនោះឡើយ។

ការធានានូវភាពគង់វង្សនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ភារកិច្ច និងសាធារណជនទូទៅ អាស្រ័យលើការបង្កើនការយល់ដឹង អំពីសក្ដានុពលនៃការអប់រំពហុភាសាក្នុងការលើកកម្ពស់សុខុដុមនីយកម្មក្នុងសង្គម ក៏ដូចជាការចូលរួមក្នុងការទទួលបានសេវាអប់រំ។

## មេរៀនសំខាន់ៗដែលទទួលបាន

ខាងក្រោមនេះ ជាមេរៀនសំខាន់ៗទទួលបាន ដែលមានភាពពាក់ព័ន្ធយ៉ាងទូលំទូលាយ ជាមួយនឹងការអនុវត្តការអប់រំពហុភាសា ក្នុងវិស័យអប់រំ។

**ភាពពាក់ព័ន្ធ៖** គ្រូជនជាតិដើមភាគតិច និងកម្មវិធីដែលឆ្លុះបញ្ចាំងពីវប្បធម៌របស់ជនជាតិដើមភាគតិច គឺជាគន្លឹះសម្រាប់ជំរុញឱ្យកុមារជនជាតិដើមភាគតិច មកចូលរៀនក្នុងសាលារៀន និងអាចទទួលបានការគាំទ្រដល់ការអប់រំ ពីឪពុកម្ដាយរបស់ពួកគេ។

**ប្រសិទ្ធភាព ៖** អ្នកកាន់ការកិច្ចនៅថ្នាក់ក្រោមជាតិ និងគ្រូជនជាតិដើមភាគតិច មានទឹកចិត្តខ្ពស់ក្នុងការពង្រីកសេវាអប់រំពហុភាសាដល់កុមារ និងសហគមន៍ដែលប្រើប្រាស់ភាសាជនជាតិភាគតិច ឱ្យកាន់តែច្រើនជាងមុន ប៉ុន្តែវាអាស្រ័យលើការគាំទ្រហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីជំរុញឱ្យមានការចូលរួមបន្ថែម ពីជនជាតិដើមភាគតិច ដូចជា គ្រូឧទ្ទេសជនជាតិដើមភាគតិច គ្រូបង្រៀនជនជាតិដើមភាគតិច និងការចូលរួមរបស់អង្គការជនជាតិភាគតិចជាដើម។

**ភាពស័ក្តិសិទ្ធិ៖** អ្នកអប់រំមានការលើកទឹកចិត្តខ្ពស់ក្នុងការធានាការអប់រំសម្រាប់ទាំងអស់គ្នា ប៉ុន្តែពួកគេត្រូវទទួលបានការបណ្តុះបណ្តាលវិក្រឹត្យការខាងការអប់រំពហុភាសា និងការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមទៀត ដើម្បីពង្រីកឱកាសទទួលបានការអប់រំប្រកបដោយអត្ថន័យ និងសមធម៌ ដល់សហគមន៍ជនជាតិដើមភាគតិច ដែលពិបាកចុះទៅដល់។



*ថតដោយ © UNICEF Cambodia/2018/Jessica Ball*



*ថតដោយ © UNICEF Cambodia/2018/Jessica Ball*

**ផលជះរយៈពេលវែង៖** ការប្រើប្រាស់ភាសាជនជាតិភាគតិចក្នុងការអប់រំ បង្កើនការចូលរួមក្នុងការអប់រំ ផ្តល់ឱកាសឱ្យកុមារទាំងអស់អាចចេះពីរភាសា លើកកម្ពស់ភាពចុះសម្រុងគ្នាក្នុងសង្គម និងធានាបាននូវភាពគង់វង្សយូរអង្វែងនៃភាសា និងវប្បធម៌។

អង្គការមិនមែនរដ្ឋាភិបាលដែលមានបទពិសោធន៍ផ្តល់ការអប់រំក្រៅប្រព័ន្ធដល់សហគមន៍ជនជាតិភាគតិចអាចជួយតួអង្គនានារបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះតម្រូវការគ្រូអប់រំពហុភាសាសម្រាប់សាលាបឋមសិក្សា និងការអប់រំអក្ខរកម្មមនុស្សពេញវ័យ ដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច។

**និរន្តរភាព៖** នាយកដ្ឋានជំនាញក្នុងក្រសួងអប់រំយុវជន និងកីឡា មានសក្តានុពលប្រមូលកិច្ចខិតខំប្រឹងប្រែង និងបំពេញការទទួលខុសត្រូវក្នុងការសម្រេចឱ្យបាននូវសមធម៌សម្រាប់កុមារ ដែលនិយាយភាសាជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ ការសហការអន្តរនាយកដ្ឋានមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាឱ្យ

មានការផ្ដល់សមត្ថភាពបច្ចេកទេស និងធនធានដែលចាំបាច់ពីនាយកដ្ឋានពាក់ព័ន្ធនានា។

ការធានាឱ្យមានការប្រើប្រាស់ភាសាជនជាតិដើមភាគតិចក្នុងសេវាអប់រំ អាស្រ័យលើការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាល ដើម្បីជួយឱ្យកុមារជនជាតិដើមភាគតិច អាចទទួលបានការអប់រំប្រកបដោយដោយអត្ថន័យ និងចាត់ទុកភាសាជនជាតិដើមភាគតិចជារតនៈសម្បត្តិរបស់ជាតិ និងជាមធ្យោបាយ ដើម្បីលើកកម្ពស់ការចុះសម្រុងគ្នានៅក្នុងសង្គម ដែលចាំបាច់ត្រូវមានការផ្សព្វផ្សាយឱ្យបានច្បាស់លាស់ពីការប្ដេជ្ញាចិត្តបែបនេះ។

**ជារួម៖** ប្រទេសកម្ពុជា គឺជាប្រទេសនាំមុខគេក្នុងតំបន់ ដែលបានបង្ហាញពីគោលវិធីស្ថាប័នក្នុងការលើកកម្ពស់ការបញ្ចូលកុមារជនជាតិដើមភាគតិចទៅក្នុងការអប់រំ តាមរយៈការប្រើប្រាស់ភាសាជនជាតិដើមភាគតិច ភាសាជាតិ និងកម្មវិធីសិក្សាដែលឆ្លើយតបទៅនឹងវប្បធម៌។ គោលវិធីបែបនេះធ្វើឱ្យការចូលរៀន កាន់តែមានលក្ខណៈមេត្រីភាពសម្រាប់កុមារ។ វាធ្វើឱ្យមេរៀនកាន់តែស្រួលយល់ និងមានភាពពាក់ព័ន្ធចំពោះកុមារ ដែលជារឿយៗជាអ្នករស់ក្នុងសហគមន៍ដាច់ស្រយាលនៅជនបទ និងដាច់ស្រយាល ដែលមានប្រជាពលរដ្ឋជាច្រើនគ្រួសារមិនចេះនិយាយភាសាជាតិ។

## អនុសាសន៍សំខាន់ៗ

អនុសាសន៍ផ្អែកតាមភស្តុតាង ដែលបានពីការវាយតម្លៃនេះ ត្រូវបានយកមករៀបរាប់ដូចខាងក្រោម ទៅតាមលំដាប់លំដោយជាអាទិភាព។ តួអង្គសំខាន់ៗ រួមមានក្រសួងអប់រំ យុវជន និងកីឡា ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ធ្វើការសហការជាមួយនឹងអ្នកកាន់ភារកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាន់សិទ្ធិចម្បង ដូចជាអង្គការជនជាតិដើមភាគតិច កុមារ និងមាតាបិតាជាជនជាតិដើមភាគតិចជាដើម។

**បរិយាបន្ន**

១. **រៀបចំផែនការលើកកម្ពស់បរិយាបន្ន៖** បន្តរៀបចំផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ជាមួយនឹងយុទ្ធសាស្ត្រ និងសកម្មភាពដែលមានការប៉ាន់ប្រមាណចំណាយត្រឹមត្រូវ និងការរៀបចំការទទួលខុសត្រូវការរៀបចំ របាយការណ៍ និងការវាយតម្លៃឱ្យបានច្បាស់លាស់។ ពង្រីកការអនុវត្តផែនការសកម្មភាពនេះជាបណ្តើរៗ ដើម្បីបញ្ចូលភាសាជនជាតិដើមភាគតិចបន្ថែមទៀត។

**ប្រព័ន្ធ**

២. **បំពេញលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពសាលាមត្តេយ្យ៖** បង្កើនគុណភាពការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា និងធ្វើសុខដុមនីយកម្មការអប់រំពហុភាសាជាមួយនឹងការអប់រំតាមសាលាមត្តេយ្យទូទៅ។ ជួយឱ្យសាលាមត្តេយ្យអាចបំពេញតាមលក្ខណៈវិនិច្ឆ័យ គុណភាពយោងតាមប្រកាសលេខ ២៤៥ ដើម្បីឱ្យសាលាទាំងនេះ ក្លាយជាឧបសម្ព័ន្ធនៃសាលាបឋមសិក្សាពហុភាសា និងបន្ទាប់មកក្លាយទៅជាសាលាមត្តេយ្យរដ្ឋ។

**គុណភាព**

៣. **ពង្រឹងសមត្ថភាពប្រព័ន្ធ៖** ពង្រឹងសមត្ថភាពបច្ចេកទេស និងប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់អនុវត្តផែនការនេះ ។ បង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការ គាំទ្របច្ចេកទេសដល់មន្ទីរអប់រំខេត្តសម្រាប់ការបណ្តុះបណ្តាលគ្រូ និងការពិនិត្យតាម ដាន។ ជ្រើសរើសមន្ត្រី ដែលចេះនិយាយភាសាជនជាតិដើមភាគតិច នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អភិវឌ្ឍចំណេះដឹង និងជំនាញអប់រំពហុភាសាដល់នាយកដ្ឋានអប់រំ ពិសេស។ បង្កើតនូវរចនាសម្ព័ន្ធស្ថាប័ន សកម្មមួយ ក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យមានការសហការអន្តរនាយកដ្ឋានជាប្រចាំ។

**គ្រូបង្រៀន**

៤. **កសាងសមត្ថភាពបង្រៀន៖** បង្កើនបរិមាណ គុណភាព និងការរក្សាគ្រូនៅតាមសាលាបឋមសិក្សាអប់រំពហុភាសា និងគ្រូឧទ្ទេសជនជាតិដើមភាគតិច តាមរយៈការបង្កើនការគាំទ្រ

ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់អ្នកកាន់ភារកិច្ចនៅថ្នាក់ក្រោមជាតិ សម្រាប់ការងារបណ្តុះបណ្តាល ពិនិត្យតាមដានបន្ថែមគ្រូឧទ្ទេសជនជាតិដើមភាគតិច និងពង្រីកការសហការជាមួយនឹងអង្គការជនជាតិដើមភាគតិច។ ជួយរៀបចំសាលាគរុកោសល្យខេត្ត ក្នុងការផ្តល់ការ បណ្តុះបណ្តាលដល់គ្រូជនជាតិដើមភាគតិច ឱ្យចេះផ្តល់ការអប់រំពហុភាសា។

**កម្មវិធីសិក្សា**

**៥. កែសម្រួលកម្មវិធីសិក្សាបង្រៀន និងរៀនផ្នែកអប់រំពហុភាសា៖** ពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សា និងធនធានសម្រាប់ការអប់រំពហុភាសា ដើម្បីកែលម្អកម្មវិធីសិក្សា ធ្វើឱ្យខ្លឹមសារវប្បធម៌កាន់តែមានលក្ខណៈសម្បូរបែប និងបញ្ចូលធនធាន ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល។ ជំរុញឱ្យមានការចូលរួមពីកុមារជនជាតិដើមភាគតិច សមាជិកសហគមន៍ និងអង្គការនានា ក្នុងការអភិវឌ្ឍធនធានបង្រៀន និងរៀនឱ្យបានជាប់ជាប្រចាំ។

**ការផ្សព្វផ្សាយ**

**៦. ផ្សព្វផ្សាយពីគុណតម្លៃ នៃភាសាជនជាតិភាគតិច៖** បង្កើនការយល់ដឹងអំពីសិទ្ធិកុមារ និងគុណតម្លៃសង្គមនៃភាសា និងវប្បធម៌ជនជាតិដើមភាគតិច តាមរយៈការរៀបចំជាយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ និងការពន្យល់ពីទស្សនទានទាំងនេះឱ្យរឹតតែស៊ីជម្រៅបន្ថែមទៀតដល់គ្រូបង្រៀន គ្រូឧទ្ទេស និងមន្ត្រីដែលទទួលបន្ទុកការងារបណ្តុះបណ្តាល។

**ទិន្នន័យ**

**៧. ធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធព័ត៌មាន៖** ធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធគ្រប់គ្រងការអប់រំ ដូចជា បែងចែកព័ត៌មានតាមយេនឌ័រ ជាតិពន្ធុ និងភាសា កត្តាកំណត់ដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីកំណត់ថា តើសេវាបានដល់ក្រុមគោលដៅអាទិភាព ទិន្នន័យតាមប្រព័ន្ធឌីជីថលទទួលបាន និងការរៀបចំរបាយការណ៍ទៅតាមស្តង់ដារ។

**ការស្រាវជ្រាវ**

**៨. ផ្តល់លទ្ធភាពឱ្យមានការស្រាវជ្រាវ និងការអភិវឌ្ឍ៖** អភិវឌ្ឍភាពជាដៃគូរវាងសាកលវិទ្យាល័យក្នុងស្រុក និងសាកលវិទ្យាល័យអន្តរជាតិ ដើម្បីរៀបចំតេស្តលទ្ធផលសិក្សាដែលប្រើប្រាស់ភាសាជនជាតិដើមភាគតិច ធ្វើការសិក្សាពីការអនុវត្តដែលមានសក្តានុពល ដូចជាការពង្រីកការអប់រំពហុភាសាដល់ថ្នាក់ទី ៦ និងវាយតម្លៃលទ្ធផលនៃការអប់រំពហុភាសាជាដើម។

PROFESSOR JESSICA BALL & MARIAM SMITH (សហប្រធាន)

ដោយមានការគាំទ្រពីសមាជិកក្រុមនៅកម្ពុជា ដូចជា៖ ស្រោម ប៊ុនធី, សាម៉ន ឡាមី, ភ្លឿក តារម្យ, ស្រី ម៉ៅ, កៅ មុំ, ធុក ប៊ុន, ជឿន ខាំតិន, ចាប់ អេ, ពិន ខៀវ

សម្រាប់របាយការណ៍លម្អិត សូមមើលទៅមើលគេហទំព័រ៖ HTTPS://WWW.UNICEF.ORG/CAMBODIA

unicef

for every child